# II- ការិយាល័យបណ្ណាក្រសួង

## ១. ធីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ១៩៩៤

### ប្រកាសអន្តរក្រសួង លេខ ២៧៥ ប្រកសហវ
### ស្តីពីការប្រមូលពន្ធ និង ត្រួតពិនិត្យការបង់ពន្ធលើមធ្យោបាយ
### ដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ១៩៩៤

ទេសរដ្ឋមន្ត្រីទីធជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៩១ ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះ គ្រប់ប្រភេទ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ២៤ ក្រ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩១
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ
- បានឃើញច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- យោងតាមការចាំបាច់ក្នុងការងារប្រមូលពន្ធ និង ការត្រួតពិនិត្យការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យាន ជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ ១៩៩៤

### សំរេច

**ប្រការ ១ :** - មុខសញ្ញាត្រូវជាប់ពន្ធ និង ត្រូវបានលើកលែងពន្ធ :

ក_ត្រូវជាប់ពន្ធគ្រប់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទទោះជារបស់រដ្ឋក៏ដោយ ដែលធ្វើចរាចរ នៅ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ_ត្រូវបានលើកលែងមិនប្រមូលពន្ធនេះចំពោះ ៖

_រថយន្តសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យ

_មធ្យោបាយដឹកជញ្ជូន និងយានជំនិះសំរាប់ដឹកសំភារៈកងទ័ព ឬបំរើការប្រយុទ្ធ

_មធ្យោបាយដឹកជញ្ជូន និង យានជំនិះរបស់ស្ថានទូត ឬ អង្គការសហគមអន្តរជាតិ ដែលបោះទីតាំងធ្វើសកម្មភាព សន្តិសុខ មនុស្សធម៌ ... ។

_មធ្យោបាយដឹកជញ្ជូន និង យានជំនិះនៃប្រទេសជិតខាងដែលធ្វើចរាចរក្នុងរយៈពេលតិចជាង ៣ ខែ នៅក្នុងព្រះ រាជាណាចក្រកម្ពុជា

**ប្រការ ២ :** _រូបភាពប័ណ្ណ និង កន្លែងបិទប័ណ្ណសំគាល់ :

## ក.ប័ណ្ណរង្វង់មូល :

_ប័ណ្ណរង្វង់មូលមានពណ៌បៃតងចាស់ សំរាប់បិទលើរថយន្ត និង ត្រាក់ទ័រគ្រប់ប្រភេទនៅខាងលើបំផុតមានអក្សរ " ព្រះរាជាណាចក្រកម្ពុជា " រាងកោងនៅខាងក្រោមបំផុតមានអក្សរ " ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " រាងកោងនៅចំ កណ្តាលមានអក្សរ " ប័ណ្ណបង់ពន្ធលើរថយន្ត " កាត់ចំកណ្តាលលេខ ៩៥ ហើយនិងនៅខាងក្រោមលេខ ៩៥ មានលេខ រៀងសំគាល់សន្លឹកប័ណ្ណ

_ត្រូវបិទប័ណ្ណសំគាល់នៅលើកញ្ចក់មុខនៃរថយន្ត ឬ ត្រាក់ទ័រ ផ្នែកខាងស្តាំជ្រុងខាងលើ ( មើលពីខាងមុខ )

## ខ.ប័ណ្ណរាងត្រីកោណ :

_ប័ណ្ណរាងត្រីកោណមានពណ៌ទឹកប៊ិច សំរាប់បិទលើទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ :

នៅខាងលើបំផុតមានអក្សរ " ព្រះរាជាណាចក្រកម្ពុជា "

នៅខាងក្រោមបំផុតមានអក្សរ " ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " នៅចំកណ្តាលមានអក្សរ "ប័ណ្ណបង់ពន្ធលើទោចក្រយានយន្ត " កាត់ចំកណ្តាលលេខ ៩៥ នៅចំខាងក្រោមលេខ ៩៥ មានលេខសំគាល់សន្លឹកប័ណ្ណ

_ត្រូវបិទប័ណ្ណសំគាល់នៅចុងតំរបកក់ខាងមុខនៃទោចក្រយានយន្ត

-ចំពោះត្រីចក្រយានយន្ត ត្រូវបិទប័ណ្ណសំគាល់នៅទីឯធុងរបស់វាផ្នែកខាងក្រោយ

**គ.ចំណុចរាងពងក្រពើ :**

-ប័ណ្ណរាងពងក្រពើមានពណ៌លឿងទុំ សំរាប់បិទលើជលយាន និង ជលយានយន្តគ្រប់ប្រភេទ :

នៅខាងលើបំផុតមានអក្សរ " ព្រះរាជាណាចក្រកម្ពុជា "

នៅខាងក្រោមបំផុតមានអក្សរ " ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " រាងកោងនៅចំកណ្តាលមានអក្សរ " ប័ណ្ណបង់ ពន្ធលើជលយាន " កាត់ចំកណ្តាលលេខ ៩៤ នៅខាងក្រោមលេខ ៩៤ មានលេខសំគាល់ប័ណ្ណ

-ត្រូវបិទប័ណ្ណសំគាល់នៅផ្នែកខាងមុខ ( កន្លែងអ្នកបើកបរ ) នៃជលយាន និង ជលយានយន្ត ។

**ប្រការ ៣ :** -អំពីរបៀបប្រមូលពន្ធ ការត្រួតពិនិត្យ ការបង់ពន្ធ និង ការផាកពិន័យ :

ក-ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ១៩៩៤ ត្រូវចាប់ប្រមូលពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៤ រហូតដល់ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ នៅគ្រប់ទីស្នាក់ការពន្ធដារ តាមការកំណត់ក្នុងមាត្រា ២ ថ្មីនៃច្បាប់ស្តីពី ការបង្កើតពន្ធលើមធ្យោបាយ និងយានជំនិះគ្រប់ប្រភេទដែលបានកែប្រែដោយមាត្រា ៥៣ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤ ដូចមានតារាងឧបសម្ព័ន្ធទី ១ និងទី ២ ភ្ជាប់ជាមួយប្រកាសនេះ ។

ខ-ចាប់ពីថ្ងៃទី ០១ ខែ មិនា ឆ្នាំ ១៩៩៥ តទៅភ្នាក់ងារពន្ធដារ សហការជាមួយនគរបាលចរាចរ នឹងធ្វើការត្រួតពិនិត្យចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ដែលធ្វើចរាចរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

គ-ចំពោះម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទដែលគេចវេះ មិនព្រមបង់ពន្ធនេះ ត្រូវរងការពិន័យ ចំនួនមួយដងស្មើនឹងប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ ។

ឃ-ត្រូវបានផ្តល់រង្វាន់លើកទឹកចិត្តចំពោះភ្នាក់ងារនគរបាលចរាចរ ភ្នាក់ងារពន្ធដារ ដែលបានរកឃើញករណីល្មើស ច្បាប់ ។ ប្រាក់រង្វាន់នេះត្រូវបានអនុញ្ញាតអោយដកចំនួន ៥០ ៗ នៃចំនួនប្រាក់ពិន័យ សំរាប់ធ្វើការបែងចែកដូចតទៅ :

-៧០ ៗ នៃប្រាក់រង្វាន់សំរាប់បែងចែកជូនរង្វាន់ដល់អ្នកចូលរួមត្រួតពិនិត្យរកឃើញអំពើល្មើសច្បាប់

-៣០ ％នៃប្រាក់រង្វាន់ទុកសំរាប់បង្កើតជាមូលនិធិរង្វាន់សរសើររបស់អង្គការពន្ធដារ(១៥ ％ សំរាប់នាយកដ្ឋាន និង ១៥ ％ សំរាប់សាខាពន្ធដារខេត្ត - ក្រុង )

ចំពោះប្រាក់ពិន័យនៅសល់ ៥០ ％ ពីការដករង្វាន់នោះត្រូវបង់ចូលថវិការដ្ឋ ។

**ប្រការ ៤ :** -ប្រធាននាយកដ្ឋានពន្ធដារ អគ្គនាយកនគរបាលជាតិ និង ប្រធាននាយកដ្ឋាន នៃក្រសួងទាំងពីរដែលមានការពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

| សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **ស ខេង ហូ សុខ** | **គាត ឈន់** |

***

*រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤*

# តារាងឧបសម្ព័ន្ធស្តីពីប្រាក់ពន្ធត្រូវកំណត់
# ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ

( តារាងឧបសម្ព័ន្ធទី ១ )

ភ្ជាប់ជាមួយប្រកាសអន្តរក្រសួងលេខ ២៧៥ ប្រក.សហវ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤

| ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ | កំរិតប្រាក់ពន្ធសំរាប់ ១ ឆ្នាំ ក្នុងមួយគ្រឿង | |
|---|---|---|
| -រថយន្តដឹកទំនិញ ធុនធ្ងន់ | ១៥០ ០០០ | |
| -រថយន្តដឹកទំនិញ ធុនស្រាល | ៧៤ ០០០ | |
| -រថយន្តដឹកអ្នកដំណើរឆ្លងកាត់ខេត្ត.ក្រុង ធុនធំ មានលើសពី ៣០ កៅអី | ១២០ ០០០ | |
| -រថយន្តដឹកអ្នកដំណើរឆ្លងកាត់ខេត្ត.ក្រុង ធុនមធ្យម មាន ៣០ កៅអីចុះ | ៩០ ០០០ | |
| - រថយន្តដឹកអ្នកដំណើរក្នុងក្រុងធុនធំ មានលើសពី ៣០ កៅអី | ៩០ ០០០ | |
| -រថយន្តដឹកអ្នកដំណើរក្នុងក្រុង ធុនមធ្យម មាន ៣០ កៅអីចុះ | ៦០ ០០០ | |
| -រថយន្តទេសចរណ៍ គ្រប់ប្រភេទ | គិតពីឆ្នាំផលិត | |
| | ដល់ ៥ ឆ្នាំ | លើសពី ៥ ឆ្នាំ |
| -កម្លាំងដល់ ៩ សេះ | ៥០ ០០០ | ៣៧ ៥០០ |
| -កម្លាំងលើសពី ៩ សេះ ដល់ ១២ សេះ | ៧៥ ០០០ | ៥០ ០០០ |
| -កម្លាំងលើសពី ១២ សេះ ឡើងទៅ | ១២៥ ០០០ | ៨៧ ៥០០ |

| | |
|---|---|
| - ...ទ័រកម្លាំង ៨២ សេះ | ១៥ ០០០ |
| - ត្រាក់ទ័រកម្លាំង ៦៥ សេះ | ៩ ០០០ |
| - ត្រាក់ទ័រកម្លាំង ៣៥ សេះ | ៣ ០០០ |
| - ទោចក្រយានយន្តទំហំពិសស្តុង ៧០ ស.ម៣ ចុះ | ៣ ០០០ |
| - ទោចក្រយានយន្តទំហំពិសស្តុង ៧០ ស.ម ៣ ទៅ ១២០ ស.ម ៣.... | ៤ ៥០០ |
| - ទោចក្រយានយន្តទំហំពិសស្តុង ១២៥ ស.ម ៣ ឡើងទៅ ... | ៧ ៥០០ |
| - ត្រីចក្រយានយន្តដឹកទំនិញ ឬ អ្នកដំណើរ | ១៥ ០០០ |
| **ជលយាន ឬ ជលយានយន្ត ផ្លូវទន្លេ ៖** | |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ៣០ ម៉ែត្រ | ១៥០ ០០០ |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ២០ ម៉ែត្រ ដល់ ៣០ ម៉ែត្រ | ១០០ ០០០ |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយ ២០ ម៉ែត្រ ចុះ | ៥០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងពី ៣០ សេះ ដល់ ៥០ សេះ | ៩ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងពី ៥០ សេះ ដល់ ១០០ សេះ | ១៥ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងពី ១០០ សេះ ដល់ ១៥០ សេះ | ២៤ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងពី ១៥០ សេះ ដល់ ២០០ សេះ | ៣០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងពី ២០០ សេះ ដល់ ២៥០ សេះ | ៩០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ២៥០ សេះ | ១៥០ ០០០ |
| - កាណូតនេសាទមានកំលាំងពី ១០ សេះ ទៅ ៥០ សេះ | ៣ ០០០ |
| - កាណូតនេសាទមានកំលាំងពី ៥០ សេះ ទៅ ១០០ សេះ | ៩ ០០០ |
| - កាណូតនេសាទមានកំលាំងពី ១០០ សេះ ទៅ ១៥០ សេះ | ១៥ ០០០ |
| - ទូកម៉ាស៊ីនចំហៀង " ជើងបង្កង " | ៥ ០០០ |
| - អូប័រ | ២៥០ ០០០ |
| **ជលយាន ឬ ជលយានយន្ត ផ្លូវសមុទ្រ ៖** | |
| - កប៉ាល់ដឹកទំនិញដែលផ្ទុកបានត្រឹម១០០០ តោនត្រូវគិតដូចផ្នែកទឹក... | |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ១ ០០០ តោន ដល់ ២ ០០០ តោន | ៣៥០ ០០០ |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ២ ០០០ តោន | ១ ២០០ ០០០ |
| - កប៉ាល់នេសាទដែលមានកំលាំងត្រឹម ១៥០ សេះត្រូវគិតដូចខាងផ្នែកទឹកសាប | |

| | |
|---|---|
| -កប៉ាល់នេសាទមានកំលាំងលើសពី ១៥០ សេះ ដល់ ២៥០ សេះ | ១៥០ ០០០ |
| -កប៉ាល់នេសាទមានកំលាំងលើសពី ២៥០ សេះ ដល់ ៥០០ សេះ | ៣០០ ០០០ |
| -កប៉ាល់នេសាទមានកំលាំងលើសពី ៥០០ សេះ ឡើងទៅ | ៦០០ ០០០ |

-កប៉ាល់សណ្តោងដែលមានកំលាំងត្រឹម ២៥០ សេះត្រូវគិតដូចខាងផ្នែកទឹកសាប

| | |
|---|---|
| -កប៉ាល់សណ្តោងមានកំលាំងលើសពី ២៥០ សេះ ដល់ ៥០០ សេះ | ១៥០ ០០០ |
| -កប៉ាល់សណ្តោងមានកំលាំងលើសពី ៥០០ សេះ ឡើងទៅ | ៣០០ ០០០ |

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ហត្ថលេខា និង ត្រា
**ស ខេង ហូ សុខ**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
**គាត ឈន់**

***

## ការវាយតម្លៃពន្ធកំណត់កំលាំងសេះរបស់យានជំនិះ « ការវាយតម្លៃពន្ធទី ២ »

## ភ្ជាប់ជាមួយប្រកាសអន្តរក្រសួងលេខ ២៧៥ ប្រក. សហវ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤

| ល.រ | ប្រភេទយានជំនិះដែលប្រើប្រាស់ថាមពល | ចំនួន CC រំលូម | កំលាំងគិតជាសេះ | ប្រាក់ពន្ធត្រូវបង់ គិតឆ្នាំផលិត ដល់ ៥ ឆ្នាំ | គិតឆ្នាំផលិត លើសពី ៥ ឆ្នាំ | [illegible] |
|---|---|---|---|---|---|---|
| ១ | សាំង | ដល់ ១ ៥០០ CC | ដល់ ៨ សេះ | ៥០ ០០០ | ៣៧ ៥០០ | [illegible] |
| ២ | ម៉ាហ្សូត | ដល់ ២ ២០០ CC | ដល់ ៨ សេះ | ៥០ ០០០ | ៣៧ ៥០០ | [illegible] ២.២ |
| ៣ | សាំង | លើសពី ១ ៥០០ CC ដល់ ២ ០០០CC | លើសពី ៨ សេះ ដល់ ១២ សេះ | ៧៥ ០០០ | ៥០ ០០០ | និយមហៅ ១.៦ ដល់ ២ |
| ៤ | ម៉ាហ្សូត | លើសពី ២ ២០០ CC ដល់ ៣ ០០០CC | លើសពី ៨ សេះ ដល់ ១២ សេះ | ៧៥ ០០០ | ៥០ ០០០ | និយមហៅ ២.៤ ដល់ ៣ |
| ៥ | សាំង | លើសពី ២ ០០០ CC ឡើងទៅ | លើសពី ១២ សេះ ឡើងទៅ | ១២៥ ០០០ | ៨៧ ៥០០ | និយមហៅ ២.២ ឡើងទៅ |
| ៦ | ម៉ាហ្សូត | លើសពី ៣ ០០០ CC ឡើងទៅ | លើសពី ១២ សេះ ឡើងទៅ | ១២៥ ០០០ | ៨៧ ៥០០ | និយមហៅ ៣.៤ ឡើងទៅ |

**ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ហត្ថលេខា និង ត្រា**

**គាត ឈន់**

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា និង ត្រា**

**ស ខេង          ហ៊ូ សុខ**